**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
លេខ៖ ៣៣៣/២៥ គ.ជ.ប.ជ.

**សូមគោរពជូន**
**ឯកឧត្តម នាយឧត្តមសេនីយ៍ សេង យូអ៊ាន់ អគ្គនាយក**
**នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ**

**កម្មវត្ថុ៖** សំណើសុំផ្ដល់កិច្ចសហការ និងសូមចាត់មន្ត្រីពេទ្យ ចំនួន ០៣រូប និងរថយន្តសង្គ្រោះបន្ទាន់ ០១គ្រឿង ដើម្បីរៀបចំផលិតវីដេអូ បទយកការណ៍សម្រាប់ផ្សព្វផ្សាយ ក្នុងកម្មវិធីទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៥ ។

**យោង៖** ចំណារដ៏ខ្ពង់ខ្ពស់បំផុត ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២៥ របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ** មេត្តាជ្រាបថា អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សហការជាមួយក្រុមហ៊ុន សាស្ត្រាហ្វីម (Sastra Film Production) ដើម្បីផលិតជាវីដេអូបទយកការណ៍សម្រាប់ផ្សព្វផ្សាយ ក្នុងកម្មវិធីទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០២៥។

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សូមគោរពស្នើសុំ **ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គនាយក** ដើម្បី **ផ្តល់កិច្ចសហការ និងសូមចាត់មន្ត្រីពេទ្យ ចំនួន ០៣រូប និងរថយន្តសង្គ្រោះបន្ទាន់ ០១គ្រឿង ។**

**កម្មវិធីថតនឹងប្រព្រឹត្តទៅនៅ៖ ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥ វេលាម៉ោង ០៧:០០ នាទីយប់ ។**

*(សូមគោរពជូនភ្ជាប់៖ កម្មវិធី ០១ច្បាប់)*

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គនាយក** មេត្តាផ្តល់កិច្ចសហការ និងសម្របសម្រួលតាមការស្នើសុំ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គនាយក** មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅពីនាងខ្ញុំ។ ៥.៦

*ថ្ងៃ អង្គារ ១២ កើត ខែ មិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩*
*រាជធានីភ្នំពេញ,ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ២០២៥*

**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯកវេជ្ជ.ប៉ុណ្ណ សំខាន់

សូមទំនាក់ទំនង៖
លោក វ.ទោ ធន ដារ៉ាវិទ្ធ
០១៦ ៩០ ៨៩ ៨៨